HIC-IP-HRM-26/0053

# **សេចក្តីជូនដំណឹង**
## **ស្តីពី**
## **ការផ្អាកដំណើរការសកម្មភាពអាជីវកម្ម និងការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ**

ក្រុមហ៊ុនសូមជម្រាបជូនដល់ បងប្អូនកម្មករនិយោជិតទាំងអស់នៃក្រុមហ៊ុន ហាយ-ថេក អ៉ីភែរ៉ឺល (ខេមបូឌា) ឱ្យបាន ជ្រាបថា៖

យោងតាមរបាយការណ៍ចុះថ្ងៃទី**២០ ខែកក្កដា ឆ្នាំ២០២៦** តាមស្មារតីកិច្ចប្រជុំដោះស្រាយ និងដោយមានការចូលរួមសម្របសម្រួលពីលោកប្រធាននាយកដ្ឋានវិវាទការងារ អំពីការផ្អាកដំណើរការផលិតកម្មទាំងស្រុងរបស់ក្រុមហ៊ុននៅថ្ងៃទី**៣១ ខែសីហា ឆ្នាំ២០២៦** ដោយមានភាគីក្រុមហ៊ុន និងសហជីពមូលដ្ឋាន និងតំណាងកម្មករ ក្នុងកិច្ចប្រជុំសហជីព និងតំណាងកម្មករបានយល់ព្រមទទួលយកនូវការទូទាត់ប្រាក់បញ្ចប់កិច្ចសន្យាការងារដែលក្រុមហ៊ុនផ្តល់អោយដូចខាងក្រោម៖

**១. កញ្ចប់ប្រាក់ទូទាត់បញ្ចប់កិច្ចសន្យាការងាររួមមាន ៤ ចំណុច៖**

- ប្រាក់ឈ្នួលចុងក្រោយ
- ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់
- ប្រាក់បំណាច់ជួសការជូនដំណឹងមុន (គិតផ្អែកតាមអតីតភាពការងារ)
- ប្រាក់បំណាច់អតីតភាពការងារ ឆមាសទី២ នៃឆ្នាំ២០២៦ ចំនួន ៧.៥ថ្ងៃ។

**២. អត្ថប្រយោជន៍បន្ថែមសម្រាប់កម្មការិនី៖**

- **កម្មការិនីកំពុងមានផ្ទៃពោះ៖** ក្រុមហ៊ុននឹងបន្តបង់ភាគទាន ប.ស.ស. ជូនរហូតដល់ថ្ងៃសម្រាល និងផ្តល់ប្រាក់ឈ្នួលចំនួន ៥០% សម្រាប់រយៈពេល ៩០ថ្ងៃ។
- **កម្មការិនីមានកូនតូច៖** ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៥ ដុល្លារអាមេរិកសម្រាប់កូនម្នាក់ ក្នុងមួយខែ សម្រាប់កូនដែលមានអាយុពី ១៨ខែ ដល់ ៣៦ខែ។

**៣. កាលបរិច្ឆេទ និងនីតិវិធីនៃការបើកប្រាក់៖**

- បងប្អូនកម្មករនិយោជិត អាចចាប់ផ្តើមចុះឈ្មោះ និងហត្ថលេខាយល់ព្រមទទួលយកការទូទាត់ ចាប់ពីថ្ងៃទី**២១ ខែកក្កដា ឆ្នាំ២០២៦** នេះតទៅ រហូតដល់ថ្ងៃបិទដំណើរការទាំងស្រុងនៅថ្ងៃទី**៣១ ខែសីហា ឆ្នាំ២០២៦**។
- ប្រាក់ទូទាត់ទាំងអស់ នឹងត្រូវវេរចូលគណនីធនាគារ អេអិមខេ (AMK BANK) របស់បងប្អូន ក្នុងរយៈពេល **៤៨ ម៉ោង** បន្ទាប់ពីបានចុះហត្ថលេខា ឬផ្តិតមេដៃរួចរាល់។

ក្រុមហ៊ុនសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងបំពេញការងាររបស់បងប្អូនកម្មករនិយោជិតទាំងអស់កន្លងមក និងសូមជូនពរឱ្យបងប្អូនទទួលបានជោគជ័យក្នុងការងារថ្មីនាពេលអនាគត។

ហាយ-ថេក អ៉ីភែរ៉ឺល (ខេមបូឌា), ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៦

**អ្នកគ្រប់គ្រងរោងចក្រ**

HI-TECH APPAREL (CAMBODIA) CO.,LTD
KINGDOM OF CAMBODIA

**Mr. THITIPONG WONGSAYANG**

ចម្លងជូន៖

- **អ្នកគ្រប់គ្រងទូទៅ**
- **បុគ្គលិក កម្មករនិយោជិតទាំងអស់**

HI-TECH APPAREL CAMBODIA

HIC-IP-HRM-26/0053

ពិនិត្យដោយ៖

**នាយកគ្រប់គ្រងផលិតកម្មក្រៅប្រទេស**

**Mr. SIRIPONGPUKIT SUPAHKKORN**

អនុម័តដោយ៖

**ប្រធានក្រុមហ៊ុន**

**Mr. PRASIT WITANAKORN**